ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់និងការបែងចែកតំបន់គ្រប់គ្រង ក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ស្តីពីការកែប្រែតំបន់ការពារធម្មជាតិពីឧទ្យានជាតិព្រះសីហនុរាម ទៅជាឧទ្យានជាតិសមុទ្រព្រះសីហនុរាម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់និងបែងចែកតំបន់គ្រប់គ្រងក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម ដែលមានផ្ទៃសរុបទំហំ ១៩ ៣៤០(ដប់ប្រាំបួនពាន់បីរយសែសិប)ហិកតា តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះសីហនុនិងខេត្តកំពត ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកាភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាប្រសិទ្ធភាពការងារគ្រប់គ្រងឧទ្យានជាតិសមុទ្រព្រះសីហនុរាម
- ធានាការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសនិទានភាពនិងនិរន្តរភាព
- លើកកម្ពស់តួនាទីសហគមន៍មូលដ្ឋាន និងវិស័យឯកជន ក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

**មាត្រា៣ .-**

ត្រូវបានបែងចែកតំបន់គ្រប់គ្រងក្នុងឧទ្យានជាតិសបុទ្រព្រះសីហនុរាម ជា២(ពីរ)តំបន់រួមមាន៖

**១. តំបន់ប្រើប្រាស់ដោយចីរភាព** មានផ្ទៃដីសរុបទំហំ ១២ ២៤៦(ដប់ពីរពាន់ពីររយសែសិបប្រាំមួយ)ហិកតា ដែលមាននិយាមកាក្នុងឧបសម្ព័ន្ធ២។ តំបន់ប្រើប្រាស់ដោយចីរភាពត្រូវបានរៀបចំនិងគ្រប់គ្រងដោយក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តព្រះសីហនុនិងខេត្តកំពត ដោយគោរពតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិនិងបទប្បញ្ញត្តិជាធរមាន។

**២. តំបន់សហគមន៍** មានផ្ទៃដីសរុបទំហំ ៧ ០៩៤(ប្រាំពីរពាន់កៅសិបបួន)ហិកតា ដែលមាននិយាមកា ក្នុងឧបសម្ព័ន្ធ២។ តំបន់សហគមន៍ត្រូវបានរៀបចំនិងគ្រប់គ្រងដោយក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តព្រះសីហនុនិងខេត្តកំពត ដោយគោរពតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិនិងបទប្បញ្ញត្តិជាធរមាន។



N

**មាត្រា៤ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុនិងខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ......១១......អនក្រ.បក ចុះថ្ងៃទី...១៧......ខែ.មករា......ឆ្នាំ២០២២

ផែនទីកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម

ភូមិសាស្ត្រខេត្តព្រះសីហនុនិងខេត្តកំពត

